ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៦៩
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៥
សាលដីកា
លេខ : ១៩
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦ ខែមករា - ឆ្នាំ១៩៩៦ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ចាន់ សុក ជាប្រធាន
២- លោក វ៉ិន ស៊ិន ជាចៅក្រម
៣- លោក វៀល មួន ជាចៅក្រម
៤- លោក ស៊ិន ធីម ជាចៅក្រម
៥- លោក ជីវ កេង ជាចៅក្រម
ក្រឡាបញ្ជី លោក វ៉ែត ឃី

តំណាងមហាអយ្យការ លោក វ៉ិន សារឿន ជាព្រះរាជអាជ្ញា.

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១២៨ ចុះថ្ងៃទី១៨ ខែ-មករា ឆ្នាំ១៩៩៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៥២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤-របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះចាប ផន ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃភូមិស្គន់ ឃុំសូទិព ស្រុកជើងព្រៃ ខេត្ត-កំពង់ចាម ឪពុកឈ្មោះចាប ជួន "ស" ម្តាយឈ្មោះជូ រ៉ែម "រ" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះស្រី ហ៊ាង ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ីជាប្រធានភូមិស្គន់ ទីលំនៅសព្វថ្ងៃនៅភូមិស្គន់ ឃុំសូទិព ស្រុក-ជើងព្រៃ ខេត្តកំពង់ចាម ឪពុកឈ្មោះស្រី អ៊ុម "រ" ម្តាយឈ្មោះខែក អ៊ុ "រ" ។

តាមបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៥ របស់-ឈ្មោះចាប ផន បានប្តឹងមិនសុខចិត្ត នឹង សេចក្តីសំរេចនៃសាលដីកាលេខ១២៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ខាងលើ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៦៩ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៥ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៥.១២.៩២ របស់ឈ្មោះចាប ផន. ប្ដឹងសុំសិទ្ធិគ្រប់គ្រងដីស្រែដោយមូលហេតុថា ប្រធានភូមិឈ្មោះយន និង ឈ្មោះណាង បានប្រគល់ដីអោយខ្លួនយូរហើយ ក្រោយមកប្រធានភូមិឈ្មោះស្រី ហ៊ាងបានសុំចែកពាក់កណ្ដាល ខ្លួនក៏អោយ ។ មកដល់ឥឡូវឈ្មោះស្រី ហ៊ាង បានធ្វើរបងព័ទ្ធយកទាំងអស់ ។

បានឃើញសាលក្រមលេខ៤៩ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៤ របស់តុលាការខេត្តកំពង់ចាមដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៥.១២.៩២ របស់ដើមចោទឈ្មោះចាប ផន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ប្រគល់ដីកើតហេតុទំហំ ៤៥ម៉ែ × ៩០ម៉ែ / ២ ផ្នែកខាងជើងអោយទៅឈ្មោះចាប ផន កាន់កាប់និងគ្រប់គ្រងជាកម្មសិទ្ធិសំរាប់សង់លំនៅដ្ឋាន ចាប់តាំងពីពេលដែលសាលក្រមនេះចូលជាស្ថាពរ ។

៣- មុនពេលដែលសាលក្រមនេះ មិនទាន់ចូលជាស្ថាពរទេនោះ តុលាការហាមដាច់ខាតមិនអោយជនណាមួយប្រើប្រាស់ឬចាត់ចែងដីនេះឡើយ ។ ការចាត់ចែងប្រើប្រាស់ដោយបំពាន ការហាមឃាត់នេះត្រូវទុកជាមោឃៈ ហើយសាមីជនត្រូវទទួលខុសត្រូវតាមច្បាប់នូវការបំពារបំពានរបស់ខ្លួន ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធតែម១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០រៀល បូករួម៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់៧០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ ។ បើមានឧទ្ធរណ៍បង្គាប់អោយឈ្មោះស្រី ហ៊ាង សងប្រាក់៧០០០រៀលនេះទៅអោយដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រ ១ × ២០០០០០០រៀល / ១០០ ស្មើ ២០.០០០រៀល បន្ថែមទៀតដែលត្រូវដាក់ចូលថវិការរដ្ឋ ៨០ × ២០.០០០ / ១០០ ស្មើ ១៦.០០០រៀល និងបានជារង្វាន់ក្រឡាបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ២០ × ២០.០០០រៀល / ១០០ ស្មើ ៤០០០រៀល ពន្ធសមាមាត្រនេះត្រូវអោយដើមចោទបង់ទុកជាមុនសិន ទើបបង្គាប់អោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៥- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។ បើគូភាគីណាមិនសុខចិត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៥ របស់ឈ្មោះស្រី ហ៊ាង ដែលប្ដឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ៤៩ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៤ របស់តុលាការខេត្តកំពង់ចាមទាំងមូល ។

បានឃើញសាលដីកាលេខ២៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៦.០៤.៩៤ របស់ឈ្មោះស្រី ហ៊ាង ទុកជាត្រឹម។

ត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៤៩ ចុះថ្ងៃទី០៦.០៤.៩៤ របស់តុលាការខេត្តកំពង់ចាមចោលជាអសារបង់ ។

៣- ប្រគល់ដីទំហំ៤៥ម៉ែ គុណ ៩០ម៉ែ ស្ថិតនៅភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលជាដីទំនាស់ អោយទៅឈ្មោះស្រី ហាង កាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលដែលសាលដីកានេះមានអានុភាពអនុវត្ត ។

៤- បង្គាប់អោយឈ្មោះចាប ផន បង់ប្រាក់ប្រដាប់ក្តីនៅថ្នាក់សាលាឧទ្ធរណ៍ ១៣០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធផ្តឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីការកា១០.០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់ដែលឈ្មោះស្រី ហាង បានបង់រួចហើយ ដើម្បីត្រូវអោយឈ្មោះចាប ផនសងទៅឈ្មោះស្រី ហាងវិញ នៅពេលដែលសាលដីកានេះ មានអានុភាពអនុវត្ត ។

- ការលើផុតកំណត់បណ្តឹងសាទុក្ខ បង្គាប់អោយឈ្មោះចាប ផន បង់ពន្ធសាលាក្រម មួយភាគរយលើតម្លៃដីទំនាស់ដែលខ្លួនទាមទារ ។ ប្រាក់នេះត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិ ៨០ ភាគរយ និងបានជាប្រយោជន៍ដល់ហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

សាលដីកានេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី សម្រេចបើកផ្លូវសាទុក្ខរយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៩៥ របស់ឈ្មោះ-ចាប ផន ប្តឹងមិនសុខចិត្ត នឹងសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី០២.១០.៩៥ របស់ឈ្មោះចាប ផន

បានឃើញសារណាតបចុះថ្ងៃទី១១.១១.៩៥ របស់ឈ្មោះស្រី ហាង

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

- បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា

- សាលដីការបស់សាលាឧទ្ធរណ៍លេខ១២៨ ចុះថ្ងៃទី១៨.០១.៩៥ បានសម្រេចត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះចាប ផន ដែលឆ្លើយនៅពេលសវនាការថា: ខ្លួនសុំកម្មសិទ្ធិកាន់កាប់ចូលទៅស្រុក ទើបស្រុកសម្រេចកម្មសិទ្ធិបាន ។ ក្រោយមកប្រធានភូមិអោយចែកអោយខ្លួន និង ស្រី ហាង ខ្លួនទៅជួបកសិកម្មស្រុកដើម្បីដាក់ពាក្យសុំកាន់កាប់ តែលោកថា ចាំស្រុកដោះស្រាយអោយ ក្រោយមកស្រី ហាង ដាក់ពាក្យសុំកាន់កាប់ដែរ ស្រុកថាចាំស្រុកដោះស្រាយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះស្រី ហាង ដែលឆ្លើយនៅពេលសវនាការថា :



៦៧ .

នាត់មួលបង្គាប់ខ្លួនទេ ដែលថាខ្លួនអាងអំណាចនោះ ។ ស្រុកបានសំរេចអោយខ្លួនត្រឹមត្រូវតាមច្បាប់

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់រួចហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី០៩.០៣.៨៥ របស់ឈ្មោះចាប ផន ដើមចោទប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចនៃសាលដីកាឧទ្ធរណ៍លេខ២៨ ចុះថ្ងៃទី១៨.០១.៨៥ របស់សាលាឧទ្ធរណ៍ទាំងមូលធ្វើឡើងក្នុងកំហុសច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ដីទំនាស់មានទំហំ៤៥ម៉ែ គុណ ៩០ម៉ែ ដែលស្ថិតនៅភូមិស្គន់ ឃុំ-សូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលមុនឆ្នាំ១៩៧៥ ជាដីដែលគ្រប់គ្រងដោយភូមិប្រាកដមែន ។ ប៉ុន្តែនៅឆ្នាំ១៩៧៩ ស្រុកបានចេញគោលការណ៍អោយបែងចែកដល់កម្មាភិបាលភូមិ ។ ពេលនោះឈ្មោះស្រី ហ៊ាងក៏បានដីទំនាស់នេះ ហើយឈ្មោះនេះក៏បានធ្វើពាក្យសុំកាន់កាប់ដីតាមពាក្យលេខ០៥៥ ,៨៤ - ចុះថ្ងៃទី ២៥.១០.៨៤ តាមរយៈរដ្ឋអំណាចឃុំសូទិព្វត្រឹមត្រូវ មានមូលដ្ឋានច្បាស់លាស់ពិតប្រាកដ ។

- យល់ឃើញថា ឈ្មោះចាប ផនដើមចោទធ្លាប់បានគ្រប់គ្រងដីទំនាស់រួមជា-មួយសមាជិកដទៃទៀតនៃអង្គភាពភូមិមែន ។ ប៉ុន្តែនៅពេលដែលស្រុកបែងចែកដីភូមិនេះ ឈ្មោះ-ចាប ផនបានចេញផុតពីការងារភូមិរួចទៅហើយ ជាហេតុធ្វើអោយឈ្មោះនេះបាត់សិទ្ធិក្នុងការទទួលចំណែកដីរបស់ភូមិ ។ ដូចនេះឈ្មោះចាប ផនពុំមានសិទ្ធិទាមទារដីទំនាស់ដែលរដ្ឋអំណាចស្រុកបានបែងចែកទៅអោយចុងចម្លើយឈ្មោះស្រី ហ៊ាងនោះបានឡើយ ។

- យល់ឃើញថា ឈ្មោះស្រី ហ៊ាងចុងចម្លើយពិតជាបានកាន់កាប់ និងប្រើប្រាស់ដីទំនាស់ស្របតាមមាត្រា២ និង ៦២ នៃច្បាប់ភូមិបាលប្រាកដមែន ។

- យល់ឃើញថា ការប្ដឹងទាមទារជម្ងឺចិត្ត របស់ចុងចម្លើយនៅថ្នាក់តុលាការកំពូល តុលាការនេះពុំមានសមត្ថកិច្ចលើកយកមកពិនិត្យបានឡើយដោយខុសនឹងគោលការណ៍ច្បាប់ ។

- យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ២៨ ចុះថ្ងៃទី១៨.០១.៨៥ ដែលសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី : ចំពោះមុខក្ដី /

១-ទទួលបណ្ដឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី០៩.០៣.៨៥ របស់ឈ្មោះចាប ផន ដើម-ចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាឧទ្ធរណ៍លេខ២៨ ចុះថ្ងៃទី១៨.០១.៨៥ របស់សាលាឧទ្ធរណ៍

ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះចាប ផនសឹមចោទបានបង់រួចហើយចំនួន-១៨.០០០រៀលគឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងការប្រគល់ដីការកោះ១២.០០០រៀល សរុប១៦.០០០រៀល សល់៣០០០រៀលប្រគល់អោយម្ចាស់ដើមវិញ ។

បង្គាប់អោយឈ្មោះចាប ផនសឹមចោទបង់ប្រាក់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខែត្តកំពង់ចាម។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៨៦ ។